ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៦៤ ប្រក

# ប្រកាស
## ស្ដីពី
## ការកែសម្រួលប្រការ៣ នៃប្រកាសលេខ៦៣៧៥ ប្រក. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីនីតិវិធី លក្ខខណ្ឌ នៃការស្នើសុំ ការផ្ដល់ និងការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/១០៩៦/៣០ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា
- បានឃើញអនុក្រឹត្យលេខ២៧០ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្ដីពីការកែសម្រួលមាត្រា១ និងមាត្រា៧នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្ដីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បកចុះ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ៦៣៧៥ប្រក. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីនីតិវិធីលក្ខខណ្ឌនៃការស្នើសុំ ការផ្ដល់ និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការមួយ ..**

ប្រការ៣នៃប្រកាសលេខ៦៣៧៥ ប្រក. ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីនីតិវិធី លក្ខខណ្ឌនៃការសុំការផ្តល់និងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរត្រូវបានធ្វើការកែសម្រួល ដូចតទៅ៖

**ប្រការ៣ .. ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុពី១៥ឆ្នាំឡើង ត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៅស្នាក់ការនីយ៍អចិន្ត្រៃយ៍ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ឬនៅតាមស្ថានីយ៍ចល័តនៃឃុំ សង្កាត់ របស់ខ្លួន តាមការជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច។

ប្រជាពលរដ្ឋ ដែលស្នើសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរត្រូវ៖

- បង្ហាញមុខដោយផ្ទាល់ជាមួយក្រុមមន្ត្រីនគរបាលជំនាញ និងត្រូវភ្ជាប់ជាមួយនូវ៖
  - សំបុត្រកំណើតបញ្ជាក់សញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូចាស់ (ចំពោះអ្នកដែលស្នើសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា) ឬ
  - ព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរ ឬ
  - សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះកើតពីឪពុកឬម្តាយដែលមានសញ្ជាតិខ្មែរ ឬ
  - ឯកសារ ឬភស្តុតាងជាផ្លូវការដែលបញ្ជាក់ថា សាមីជនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ និង
  - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ។ ក្នុងករណីដែលមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ត្រូវមានឯកសារបញ្ជាក់ទីលំនៅដែលត្រូវកំណត់ដោយសេចក្តីណែនាំដោយឡែក។
- បំពេញសលាកប័ត្រសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយសរសេរឲ្យបានត្រឹមត្រូវច្បាស់លាស់ដូចឯកសារសំអាងភ្ជាប់មកជាមួយ
- ផ្តិតខ្មៅដៃ ថតរូប ចុះហត្ថលេខា
- បង់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តាមការកំណត់នៃប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទទួលយកបង្កាន់ដៃបង់ប្រាក់ សម្រាប់បង្ហាញអាជ្ញាធរមានសមត្ថកិច្ច នៅពេលទទួលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

មិនត្រូវបានអនុញ្ញាតផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំពោះជនទាំងឡាយណាដែល៖

- កំពុងបំពេញជាបព្វជិតក្នុងព្រះពុទ្ធសាសនា
- កំពុងអនុវត្តទោសតាមសាលក្រម ឬសាលដីការបស់តុលាការ
- វិកលចរិត

- កំពុងឋិតនៅក្នុងមណ្ឌលអប់រំកែប្រែ
- មានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ។

**ប្រការ៣ៈ**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានីខេត្ត និងបណ្ដាអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u>**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៣*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*